# ភាវេតព្វកិច្ច

អុបាសកអុបាសិកាបានទទួលសមាទាននូវអុបោសថសីល ក្នុងថ្ងៃអុបោសថកាល នោះរួចហើយ បើចង់អោយមានផលានិសង្សច្រើន ក្នុងថ្ងៃនោះយប់នោះត្រូវសង្រួមកាយវាចា អោយបានសមគួររៀបរយតាមពុទ្ធានុញ្ញាតទុកមក។

អែការសង្រួមកាយអោយបានសមគួរនោះ គឺត្រូវលះបង់នូវការងារទាំងឡាយមាន ភ្ជួរស្រែកាប់ចំការជាដើមដែលជាការសៅហ្មងដល់ព្រហ្មចារីសីល ដែលខ្លួនបានទទួលសមាទានហើយក្នុងថ្ងៃនោះយប់នោះ សង្រួមវាចាអោយបានសមគួរនោះគឺត្រូវ លះបង់នូវតិរច្ឆានកថាទាំង៣២យ៉ាង មាននិយាយអំពីបាយស្រូវអង្ករថាអាក្រក់ល្អ អំពីទឹករីអំពីដីថាក្នុងទីនេះទីនោះមានទឹកថ្លាទឹកអាក្រក់ដីល្អដីអាក្រក់ អំពីគ្រឿងស្លៀកពាក់ថាល្អអាក្រក់ អំពីញាតិរបស់ខ្លួនថាល្អ ថាចំរើនដោយសេចក្តីសុខ អំពីរូបស្រី ប្រុសថាអាក្រក់ថាល្អជាដើម ហើយគួរប្រកបពោលនូវពាក្យជាទីសប្បាយដប់ប្រការមានពោលអំពីសីល៥ សីល៨ និងអានិសង្សនៃសីល៥ សីល៨ អំពីសមាធិកម្មដ្ឋានទាំ៤០ អំពីវិបស្សនាបញ្ញាជាដើម។

បើបានសង្រួមកាយវាចាសមគួរហើយ ក្នុងថ្ងៃនោះយប់នោះ ត្រូវស្តាប់ធម៌ទេសនា រីធ្វើនូវធម្មសាកច្ឆាគឺសាកសួរអំពីធម៌ បើមិនបានស្តាប់ធម៌នោះទេ ត្រូវសង្រួម ចិត្តតាំងចំរើននូវកម្មដ្ឋានក្នុងសមថកម្មដ្ឋានទាំង៤០ ប្រការត្រង់កម្មដ្ឋានណាមួយក៏បាន អែកម្មដ្ឋានទាំង៤០ នោះមានសេចក្តីពិស្តារ នៅក្នុងគម្ពីរវិសុទ្ធិមគ្គបាលីរឺសំរាយ ត្រង់សមាធិនិទ្ទេសជានិទ្ទេទីពីរ ក្នុងទីនេះ មិនបានសំដែងអំពីកម្មដ្ឋានទាំងនោះដោយសព្វគ្រប់ទេគ្រាន់តែប្រាប់របៀប និងធម៌ដែលត្រូវចំរើននោះខ្លះប៉ុណ្ណោះ។ ពុទ្ធភាសិតសំដែងថា អ្នកនឹងចំរើនមូលកម្មដ្ឋាន គឺពុទ្ធានុស្សតិកម្មដ្ឋានជាមុនសិន ហើយទើបអោយចំរើននូវកម្មដ្ឋានអែទៀតតទៅ តាមគួរដល់អធ្យាស្រ័យ។

វិធីដែលនឹងចំរើននោះដូច្នេះ អុបាសកអុបាសិកាមុនដែលនឹងចំរើនកម្មដ្ឋាននោះ ត្រូវពិចារណានូវទោសនៃកាមគុណអោយឃើញច្បាស់ថា រូប សំលេង ក្លិន រស សម្ផស្សទាំង៥នេះរមែងកើតទោសទុក្ខផ្សេងៗ រីនឹងពិចារណានូវខន្ធ៥ អោយឃើញថាជា អនិច្ចំ ទុក្ខំ អនត្តា គឺអោយឃើញថារូបក្ខន្ធនេះមិនទៀង តែង

វិនាសទៅដោយហេតុផ្សេងៗ មានវិនាសដោយចំហាយក្តៅត្រជាក់ជាដើម រូបនេះរមែងនាំមកនូវសេចក្តីទុក្ខព្រួយ រូបនេះរមែងបែកធ្លាយជាធម្មតារកខ្លឹមសាគ្មានសោះឡើយ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណខន្ធ សោតក៏ជាអនិច្ចំ ទុក្ខំអនត្តាដូចគ្នានឹងរូបក្ខន្ធនោះដែរ។

ម្យ៉ាងទៀត គប្បីពិចារណាធម៌ដែលជាទីសង្វេគនោះថា ជនទាំងឡាយដែលកើត មកក្នុងលោកនេះរកទីពឹងពុំនាក់អោយមាំមួននោះពុំមាន សុទ្ធតែជាអ្នកកំព្រាម្នាក់អែង មានមាតាបិតាស្វាមីភរិយាកូនប្រុសស្រីមិត្តសំលាញ់មានទ្រព្យសម្បត្តិ ក៏ទុកដូចជាគ្មាន ព្រោះថា ជនទាំងឡាយមានមាតាបិតាជាដើមនោះ មិនអាចនឹងបែងចែក នូវសេចក្តីសុខទុក្ខអោយដល់គ្នាបានឡើយ មិនអាចនឹងជួយការពារ រឺជូនដំណើរគ្នាទៅក្នុងកាលដែលមរណសង្គ្រាមមកដល់ចំពោះរូបនិមួយៗនោះបានឡើយ ពេលដែលមរណសង្គ្រាមមកដល់ខ្លួនសត្វទាំងអស់ក៏ជាអ្នកអិតមានគ្នីគ្នាឡើយ បើប្រទះបានសេចក្តីទុក្ខ ដែលកើតអំពីអកុសលកម្មដែលខ្លួនធ្វើហើយ ក្នុងកាលមុនស្លាប់នោះ ក៏ត្រូវតែទទួលយកនូវសេចក្តីទុក្ខនោះដោយឆាប់រហ័យ រឺបើប្រទះបានសេចក្តីសុខដែលជាផលនៃកុសលកម្ម ដែលខ្លួនបានកសាងមកហើយក្នុងពេលមុនស្លាប់ នោះក៏ត្រូវទទួលសោយសុខដោយបរិបូណ៌ចំពោះតែខ្លួនមួយប៉ុណ្ណោះ ទោះខ្លួនមានទ្រព្យសម្បត្តិក្នុងលោកនេះតិចច្រើនប៉ុន្មានៗក្តី ក៏មិនអាចយកទៅផងបានឡើយ។

កាលបើអុបាសកអុបាសិកា បានពិចារណាដូច្នេះហើយ ក៏នឹងឃើញថា សព្វមនុស្សប្រុសស្រីទាំងអស់ នឹងរកគ្នីគ្នាមកជាទីពឹងពុំនាក់អោយបានមាំមួននោះពុំមានឡើយ ឃើញតែគុណទាំងឡាយមានគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងទានសីល ភាវនាជាដើមនេះអែង ទើបជាទីពឹងដ៏វិសេសអាចនឹងជួយអុបត្ថម្ភ គាំពារទំនុកបំរុង ក្នុងកាលដែលមច្ចុសង្គ្រាមមកដល់ ផ្តាច់ផ្តល់នូវជីវិតអិន្ទ្រិយរបស់សត្វទាំងពួងនោះ អោយសុខបានស្រួលរៀងដរាបទៅដល់លោកខាងមុខទៀតបាន។

អុបាសកអុបាសិកា កាលបើលពិចារណាឃើញសេចក្តីយ៉ាងនេះហើយ ក៏នឹងមានចិត្តអោនទៅកាន់ពុទ្ធគុណ ធម្មគុណ សង្ឃគុណ បើឃើញថាចិត្តរបស់ខ្លួនអោនទៅកាន់គុណព្រះរតនត្រៃហើយ គប្បីពិចារណានូវព្រះនាមរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំង១០ព្រះនាម មានអរហំជាដើម អោយបានកើតសេចក្តីជ្រះថ្លាក្នុងព្រះនាមទាំងនោះ ហើយគប្បីលើកឡើងនូវព្រះនាមទាំងនោះមកភាវនា គឺថាយកគុណទាំងនោះមក

នឹករំពឹងតែក្នុងចិត្តម្យ៉ាង មិនបានបញ្ចេញវាចាអោយលន់លឺឡើយ។

អែកិច្ចដែលនឹងអង្គុយចំរើនភាវនានោះ ក្នុងបាលីដែលជាពុទ្ធភាសិតបង្គាប់ថាអង្គុយពែនជើង ហើយធ្វើកាយអោយត្រង់ល្មមស្រួល បែរមុខអោយចំទៅមុខ តំកល់ស្មារតីអោយនឹង នៅក្នុងអារម្មណ៍ដែលខ្លួនបំរុងនឹងលើកឡើងមកកាន់វិធីភាវនោះ

## វិធីភាវនាមានបីយ៉ាង

១ - អោយរំពឹងថា អិតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោបុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ។ ហើយត្រឡប់មកតាំងរំពឹងពីខាងដើមទៅទៀត។ រំពឹងយ៉ាងនេះទោះ ១០០ចប់ រឺ ១០០០ចប់ ក៏បានតាមកំលាំងសទ្ធា។

២ - នឹងរំពឹងថា សោ ភគវា អិតិបិ អរហំ សោ ភគវា អិតិបិ សម្មាសម្ពុទ្ធោ សោ ភគវា អិតិបិ វិជ្ជាចរណសម្បន្នោ ។ល។ ហើយត្រឡប់មកតាំងនឹករំពឹងខាងដើមទៅទៀត រំពឹងយ៉ាងនេះទោះ១០០ចប់ រឺ ១០០០ចប់ ក៏បានតាមកំលាំងសទ្ធា។

៣ - នឹងនឹករំពឹងតែមួយបទៗ ដូចរំពឹងថា អរហំៗៗ..រឺថា សម្មាសម្ពុទ្ធោៗៗ រឺពុទ្ធោ ៗៗ រឺថា ភគវាៗៗ ដូច្នេះក៏បាន នឹករំពឹងយ៉ាងនេះក្នុង ១បទៗ ទោះបាន១រយចប់ក្តី ១ពាន់ចប់ក្តី តាមពេញចិត្តរបស់ខ្លួន ត្រូវនឹករំពឹងដោយដឹងសេចក្តីផង ដូចមានបែប ប្រែក្នុងត្រប្រែណាមខាងដើមនោះស្រាប់ហើយ។

អែទីសេនាសនៈដែលអុបាសកអុបាសិកានឹងអង្គុយចំរើននោះ គប្បីរកទីអោយស្ងាត់ ទាំងពេលសោត ក៏ត្រូវរកអោយស្ងាត់ចាកសូរសព្ទសំលេងទាំងពួង កុំអោយលាន់លឺគឹកង ដើម្បីនឹងធ្វើអារម្មណ៍អោយតាំងនៅនឹងល្អ។

កាលបើអុបាសកអុបាសិកាបានតាំងភាវនារំពឹងដល់ពុទ្ធគុណដូច្នេះហើយ ក៏នឹងអោយបានកើតបានតែត្រឹមបីតិ៥ យ៉ាងគឺ

- ១ -ខុទ្ទកា បីតិ សេចក្តីត្រេកអរព្រឺពោមព្រឺស្បែក។

- ២ -ខណិកា បីតិ សេចក្តីត្រេកអរប្រាកដដូចជាផ្លេកបន្ទោរ
- ៣ - អោក្កន្តិកា បីតិ សេចក្តីត្រេកអរមានអាការដូចជារលកទឹកបោកខ្ទប់ មកត្រូវ
- ៤ -អុព្វេង្គា បីតិសេចក្តីត្រេកអរខ្លាំងអាចញ៉ាំងកាយអោយអណ្តែតឡើង
- ៥ - ផរណាបីតិ សេចក្តីត្រេកអរ ធ្វើអោយត្រជាក់ជ្រួតជ្រាបទូទៅក្នុងកាយ។

បីតិ៥ប្រការនេះត្រង់បីតិណាមួយ រមែងកើតឡើងដោយអំណាចភាវនា រំពឹងដល់ ពុទ្ធគុណដែលជាមូលកម្មដ្ឋាន ហើយនឹងបានផលានិសង្ស អាចអោយសំរេចបាន ត្រឹមអុបចារជ្ឈានប៉ុណ្ណោះ មិនអាចនឹងអោយដល់អប្បនាឈាន  គឺបឋមឈាននោះបានឡើយ ព្រោះពុទ្ធគុណនេះ ជាគុណជ្រាលជ្រៅអនេកអនន្តពន់ពេកណាស់ អ្នកដែលចំរើននោះមិនអាចនឹងពិចារណាអោយយល់សព្វគ្រប់ទៅបាន។

ចប់ភាវេតព្វកិច្ច ដោយសង្ខេបតែប៉ុណ្ណោះ